# ប្រវេសន៍នៃការប្រតិបត្តិឯកជនភាព ព័តិមានសុខភាព

ប្រវេសន៍សង្ខេបនៃការប្រតិបត្តិឯកជនភាព

**ព័តិមានសុខភាពរបស់អ្នក**

រាល់ពេលដែលអ្នកទៅមន្ទីរពេទ្យ ឬទៅជួបវេជ្ជបណ្ឌិត ឬអ្នកផ្តត់ផ្គង់សេវាថែទាំសុខភាពផ្សេងទៀត ព័តិមានសុខភាពរបស់អ្នកនឹងត្រូវកត់ត្រាទុក ។ នេះហៅថា របាយការណ៍វេជ្ជសាស្ត្រ ។ វាអាចត្រូវបានរក្សាទុកក្នុងកុំព្យូទ័រ ឬក្រដាសដោយមានសរសេរឈ្មោះអ្នកនៅពីលើ ។ គោលនយោបាយនៃអង្គភាពជាសមាជិករបស់យើងនីមួយៗ គឺរក្សាព័តិមានសុខភាពរបស់អ្នកឱ្យមានសុវត្ថិភាព ។

**ឯកជនភាព និងព័តិមានសុខភាពរបស់អ្នក**

ដោយយោងតាមច្បាប់ ព័តិមានសុខភាពរបស់អ្នកគឺជារបស់ឯកជន ។ មន្ទីរពេទ្យ ឬអង្គភាពនីមួយៗដែលមាននៅផ្នែកចុងបញ្ចប់នៃកូនសៀវភៅនេះត្រូវឱ្យប្រវេសន៍នៃការប្រតិបត្តិឯកជនភាពនេះទៅអ្នក ។ ប្រវេសន៍នេះនឹងប្រាប់អ្នកថាព័តិមានឯកជនរបស់អ្នកនឹងត្រូវបានប្រើប្រាស់ដោយរបៀបណា ហើយអ្នកណានឹងអាចមើលរបាយការណ៍វេជ្ជសាស្ត្រ របស់អ្នកបាន ។ ទំព័រដំបូងនេះគ្រាន់តែជាសេចក្តីសង្ខេបប៉ុណ្ណោះ ។ ទំព័រក្រោយៗនឹងផ្តល់ព័តិមានលម្អិតកាន់តែច្រើន ។

**សិទ្ធិ និងព័តិមានសុខភាពរបស់អ្នក**

យោងតាមច្បាប់សហព័ន្ធអ្នកមានសិទ្ធិក្នុងការ:

- ដឹងថាពេលណាដែលរបាយការណ៍វេជ្ជសាស្ត្រនឹងត្រូវបានប្រើប្រាស់ ឬចែករំលែកជាមួយអ្នកដទៃ
- ស្នើសុំច្បាប់ចម្លងនៃរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នក
- ស្នើសុំឱ្យផ្ញើរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកទៅកាន់អ្នកផ្តត់ផ្គង់សេវាថែទាំសុខភាព ឬបុគ្គលផ្សេងទៀត
- សុំឱ្យដាក់កម្រិតលើការប្រើប្រាស់ ឬចែករំលែករបាយការណ៍វេជ្ជសាស្ត្ររបស់អ្នក
- ស្នើសុំឱ្យកែតម្រូវ ឬកែប្រែរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នក
- ស្នើសុំបញ្ជីនៃការលាតត្រដាងរបាយការណ៍វេជ្ជសាស្ត្ររបស់អ្នកដែលបានធ្វើឡើងបន្ទាប់ពីថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០០៣ ប្រសិនបើមិនត្រូវបានប្រើប្រាស់សម្រាប់ការព្យាបាល ការបង់ប្រាក់ ប្រតិបត្តិការថែទាំសុខភាពនោះទេ

**ការចែករំលែកព័តិមានសុខភាពរបស់អ្នក**

រាល់មន្ទីរពេទ្យ និងអង្គភាពដែលមានឈ្មោះនៅចុងបញ្ចប់នៃកូនសៀវភៅ អាចនឹងត្រូវការចែករំលែកព័តិមានសុខភាពរបស់អ្នកដោយសារហេតុផលដូចខាងក្រោម:

- ការព្យាបាលរបស់អ្នក
- ការបង់ប្រាក់
- ប្រតិបត្តិការថែទាំសុខភាពដូចជាការរំលឹកពីការណាត់ជួប ការពិនិត្យលើគុណភាពនៃការថែទាំ និងអត្ថប្រយោជន៍ និងសេវាកម្មដែលពាក់ព័ន្ធនឹងសុខភាព
- បញ្ជីរាយឈ្មោះមន្ទីរពេទ្យ
- បើសិនត្រូវការដោយច្បាប់

**ការការពារឯកជនភាពពិសេស**

មានរបាយការណ៍វេជ្ជសាស្ត្រមួយចំនួន ដែលត្រូវការការពារពិសេស ។ ការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នកដើម្បីធ្វើការចែករំលែករបាយការណ៍បែបនេះនឹងត្រូវការមុនពេលធ្វើការចែករំលែកជាមួយអ្នកដទៃ ។ ការការពារពិសេសអាចមានសម្រាប់របាយការណ៍ដូចខាងក្រោម:

- ការព្យាបាលសុខភាពផ្លូវចិត្ត
- លទ្ធផលធ្វើតេស្តរកមេរោគអេដស៍
- ការព្យាបាលលើការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជ្រុល

សម្រាប់ព័តិមានបន្ថែម

សូមអានព័តិមានសុខភាពនៃការប្រតិបត្តិប្រវេសន៍ឯកជនភាពនេះ ។

មានប្រសិទ្ធិភាពថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០០៣

ពិនិត្យឡើងវិញ ខែកក្កដា ឆ្នាំ ២០១២

August,2013

Revised March 4, 2015

MaineHealth

Notice of Health Information Privacy Practices Summary - Khmer (Cambodian)